ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:.....០៩៥ ប្រ.ក......ប.ស្ល

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «ភ្នំល្អាង» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិបជិវត្ត ភូមិប្រមូលផ្តុំ និងភូមិដំណាក់គ្រាច ឃុំច្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១._**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំល្អាង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតនៅភូមិបជិវត្ត ភូមិប្រមូលផ្តុំ និងដំណាក់គ្រាច ឃុំច្រាច់ ស្រុកជ័យសែន ខេត្តព្រះវិហារ។



អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៨ ០០៤/ ០២៣ ២១៨ ០០៦

**ប្រការ២.**_

សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំល្អង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» មានផ្ទៃដីសរុបទំហំ **២,១៩៣.៩៨ ហិកតា** (ពីរពាន់មួយរយកៅសិបបីកន្លក់សញ្ញាកៅសិបប្រាំបីហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 539925 | 1496051 | 15 | 535328 | 1499048 |
| 2 | 540029 | 1496219 | 16 | 535337 | 1499178 |
| 3 | 539857 | 1496703 | 17 | 535099 | 1499209 |
| 4 | 540031 | 1496836 | 18 | 535124 | 1499480 |
| 5 | 542071 | 1496439 | 19 | 535489 | 1499582 |
| 6 | 541738 | 1495349 | 20 | 535920 | 1499353 |
| 7 | 540921 | 1493967 | 21 | 536242 | 1499285 |
| 8 | 539849 | 1494010 | 22 | 536644 | 1499404 |
| 9 | 534570 | 1495994 | 23 | 536979 | 1499150 |
| 10 | 534293 | 1497044 | 24 | 536955 | 1498904 |
| 11 | 534740 | 1497106 | 25 | 537430 | 1498362 |
| 12 | 535114 | 1497857 | 26 | 537717 | 1498133 |
| 13 | 534168 | 1498252 | 27 | 537714 | 1497832 |
| 14 | 534718 | 1499086 | | | |

**ប្រការ៣.**_

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំល្អង»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.**_

សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំល្អង»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ **«ភ្នំល្អង»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ «ភ្នំត្បែង» ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

